ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

**សូមគោរពជូន**

**សម្តេចតិជោ ហ៊ុន សែន ... ... អនុប្រធានគណបក្សប្រជាជនកម្ពុជា** 

**និងជាប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចវិបុលសេនាភក្តី** អនុប្រធានគណបក្សប្រជាជនកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !

ជាបឋម តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងក្នុងនាមខ្ញុំនិងភរិយាខ្ញុំ ព្រមទាំងសមាជិក សមាជិកា ក្រុមការងារទាំងអស់ សូមសម្តែងនូវមនោសញ្ចេតនា សោមនស្សរីករាយ និងអបអរសាទរយ៉ាងកក់ក្តៅបំផុតចំពោះ **សម្តេចវិបុលសេនាភក្តី** ព្រមទាំង ក្រុមគ្រួសារ **សម្តេច** ក្នុងឱកាសដ៏ឧត្តុង្គឧត្តមថ្លៃថ្លាបំផុត ដែលសមាជិក សមាជិកា អង្គសន្និបាត គណៈកម្មាធិការកណ្តាលលើកទី៣៨ អាណត្តិទី៥ គណបក្សប្រជាជនកម្ពុជា បោះឆ្នោតជាឯកច្ឆន្ទជ្រើសតាំង **សម្តេច** ជាអនុប្រធានគណបក្សប្រជាជនកម្ពុជា នាថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១៥ ។

ការបោះឆ្នោតជ្រើសតាំង **សម្តេចវិបុលសេនាភក្តី** ជាអនុប្រធានគណបក្សប្រជាជនកម្ពុជា ពិតជាឆ្លុះបញ្ចាំងឲ្យឃើញពីសមត្ថភាព ប្រជាប្រិយភាព និងភាពជាអ្នកដឹកនាំចាស់ទុំនយោបាយ ស័ក្តិសមទៅនឹងគុណបំណាច់ និងស្នាដៃដ៏ធំធេងរបស់ **សម្តេច** ដែលបាន លះបង់កម្លាំងកាយ-ចិត្តធ្វើពលិកម្ម គ្រប់បែបយ៉ាងដើម្បីបុព្វហេតុបំរើឧត្តមប្រយោជន៍ជាតិ មាតុភូមិ និងប្រជាពលរដ្ឋ ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ឧត្តុង្គឧត្តម ប្រពៃថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវការ គោរព កោតសរសើរចំពោះ **សម្តេច អនុប្រធានគណបក្សប្រជាជនកម្ពុជា** ជាឥស្សរៈជនដ៏ឆ្នើមមួយរូប ដែលបានលះបង់កម្លាំងកាយ-ចិត្ត ប្រាជ្ញា ស្មារតីជាពិសេសនៅក្នុងការបំពេញបេសកម្មដ៏ឧត្តុង្គឧត្តមនៅក្នុងស្ថាប័ននីតិបញ្ញត្តិ **សម្តេច** បានសកម្មរួមចំណែកក្នុងការ កសាងនីតិរដ្ឋ ផ្សះផ្សា បង្រួបបង្រួមជាតិ ធ្វើអោយមានស្ថេរភាព នយោបាយ សន្តិសុខ និងអភិវឌ្ឍន៍ប្រទេសជាតិឲ្យមាន ការរីកចម្រើនលើគ្រប់វិស័យ។ ទាំងនេះពិតជាកិត្តិយសដ៏ឧត្តុង្គឧត្តមផងដែរ សម្រាប់គណបក្សប្រជាជនកម្ពុជាក៏ដូចជា សម្រាប់ខ្លួន **សម្តេច**ផ្ទាល់ និងក្រុមគ្រួសាររបស់ **សម្តេច** ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ឧត្តុង្គឧត្តម ប្រពៃថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមប្រសិទ្ធិពរជ័យ ជូនចំពោះ **សម្តេច** អនុប្រធានគណបក្ស ប្រជាជនកម្ពុជា ព្រមទាំង ក្រុមគ្រួសារ សូមប្រកបដោយ ពុទ្ធពរទាំង ៨ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអនុប្រធាន** មេត្តាទទួលនូវការគោរពស្រឡាញ់ ដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាសមាជិក**

**គណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា**

**ទៀ បាញ់**